# PRESS RELEASE

# Japanese ODA News

## Exchange of Notes for Japan's ODA Loan and Grant Aid

Under the high presence of

## Samdech Akka Moha Sena Padei Techo HUN Sen
## Prime Minister of the Kingdom of Cambodia

**March 18, 2009 at 09:00 a.m.**
**at the Ministry of Foreign Affairs and International Cooperation**

With a view to promoting the economic stabilization and development efforts of the Kingdom of Cambodia, the Government of Japan has decided to extend ODA Loan and Grant Aid to the Royal Government of Cambodia for the two following projects:

- A Loan of ¥3,513,000,000 for the Niroth Water Supply Project.
- A Grant Aid of ¥548,000,000 the Project for Improvement of Equipment for Demining Activities (Phase V).

The Notes to these effects will be exchanged under the high presence of **Samdech Akka Moha Sena Padei Techo HUN Sen, Prime Minister of the Kingdom of Cambodia**, between **H.E. Mr. HOR Namhong**, Deputy Prime Minister, Minister of Foreign Affairs and International Cooperation and **H.E. Mr. Katsuhiro SHINOHARA,** Ambassador of Japan to the Kingdom of Cambodia on March 18, 2009 at the Ministry of Foreign Affairs and International Cooperation.

**1. The Niroth Water Supply Project (¥3,513,000,000** approximately **US$35,130,000)**

The Government of Japan has a long commitment to support the water supply sector in order to secure basic human needs in Cambodia. For example water treatment plant and water supply facilities in Phnom Penh were improved and expanded in 1990s, in Siem Reap province in the early 2000s and in the peri-urban and rural provinces.

In Phnom Penh city including its surrounding area, demand for water has been increasing due to remarkable increase of population and commercial properties, and safety and steady supply of water is strongly requested.

The today's signing project which will be implemented by the Phnom Penh Water Supply Authority is to construct a new water supply station in Sangkat Niroth, Meanchey district, Phnom Penh Municipality in order to promote living condition and investment circumstances.

The concessional terms and conditions of the Loan are as follows:

1. Interest rate is 0.01% per annum.
2. Repayment period is 40 years (including 10 years period of grace).
3. Tying Status (Procurement conditions) is General Untied

Through the implementation of this project, development of water supply capacity and water quality are to be expected and also population of enjoying water supply will be increased by about 470,000 people.

**2. The Project for Improvement of Equipment for Demining Activities (Phase V) (¥548,000,000 approximately US$5,480,000)**

Recognizing the seriousness of the existence of landmines in Cambodia, the Government of Japan has supported the Cambodian Mine Action Center's (CMAC) demining activities by providing demining equipment through its Grant Aid assistance since 1999 and, including the today's signing, total assistance to CMAC is worth ¥3,907,000,000 (approx. equivalent to US$ 34.8 million).

Grant Aids for the four previous phases were provided on:

Phase I signed on 26 March 1999: ¥470,000,000 (approx. US$ 4 million)
Phase II signed on 11 May 2000: ¥330,000,000 (approx. US$ 3 million)
Phase III signed on 13 June 2002: ¥798,000,000 (approx. US$ 6.3 million)
Phase IV signed on 11 August 2004: ¥1,761,000,000 (approx. US$ 16 million)

The mains items provided for this Phase V project are mine detectors, mine/UXO detectors, spare parts and mobile workshop for brush cutter with crane. It is expected that this Phase V of the project will contribute to accelerating the demining activities of CMAC and consequently to increase further number of Cambodian people who could lead peaceful life in the clear-land.

Japan’s Mine Clearance Assistance in Cambodia

(From 1994 onward)

| | By Type of Aid | Amount in USD (Approximately) |
|---|---|---|
| 1 | Bilateral Grant Aid to CMAC (¥ 3,907,000,000) | 34,800,000 |
| 2 | UNDP Trust Fund | 11,500,000 |
| 3 | Japan-ASEAN Integration Fund (JAIF) | 376,910 |
| 4 | Peace Building and Comprehensive Small Arms Management Programme in Cambodia (¥ 910,000,000) | 8,500,000 |
| 5 | Japan’s Grassroots Human Security Grant Aid to CMAC | 11,301,368 |
| 6 | Japan’s Funding for Research and Development of New Technology (The Project for Research and Development of Mine Clearance Related Equipment (Phase I: ¥ 416,000,000), (Phase II: ¥ 484,000,000) to CMAC | 7,789,000 |
| 7 | Japan’s Grassroots Human Security Grant Aid for NGOs working in demining activities:<br>- HALO Trust (US$ 4,743,191)<br>- JAHDS (US$ 580,858)<br>- MAG (US$ 4,954,987) | 10,279,036 |
| 8 | Japan’s Grassroots Human Security Grant Aid for Japanese NGOs working in demining activities:<br>- JMAS (US$ 5,692,624) | 5,692,624 |
| 9 | Equipment for Field Survey for Pailin Municipal Development Committee | 5,536 |
| | Total | 90,244,474 |

# សេចក្ដីប្រកាសព័ត៌មាន

## ព័ត៌មានស្ដីអំពីជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន

### ពិធីចុះហត្ថលេខាលើសារលិខិតប្ដូរ

### ជំនួយកម្ចីសម្បទាន និង ជំនួយឥតសំណង ODA របស់ជប៉ុន

### ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់

### សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

**ថ្ងៃទី 18 ខែ មិនា ឆ្នាំ 2009 វេលាម៉ោង 09:00 ព្រឹក**

**នៅទីស្ដីការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតី**

ដោយឈរនៅលើទស្សនៈដើម្បីជួយជំរុញដល់កិច្ចខិតខំប្រឹងប្រែងដើម្បីរក្សាស្ថេរភាពសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍របស់ព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលជប៉ុនបានសំរេចផ្ដល់ជំនួយកម្ចីសម្បទាន និង ជំនួយឥតសំណង ODA ជូនដល់រាជរដ្ឋាភិបាលកម្ពុជាសំរាប់គំរោងចំនួនពីរខាងក្រោមនេះ:

1- ជំនួយកម្ចីសម្បទានចំនួន **¥ 3,513,000,000** សំរាប់គំរោងសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតនិរោធ

2- ជំនួយឥតសំណងចំនួន **¥ 548,000,000** សំរាប់គំរោងផ្គត់ផ្គង់សំភារៈបោសសំអាតមីន

（ដំណាក់កាលទី 5）

សារលិខិតប្ដូរនៃគំរោងជំនួយនេះទាំងពីរខាងលើនេះនឹងត្រូវចុះហត្ថលេខា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** រវាង **ឯកឧត្តម ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង **ឯកឧត្តម កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា** (Katsuhiro SHINOHARA) ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា **នៅថ្ងៃទី 18 ខែមិនា ឆ្នាំ 2009 នៅទីស្ដីការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ** ។

## 1~ គំរោងសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតនិរោធ

(¥ 3,513,000,000 ប្រហាក់ប្រហែលស្មើនឹង 35,130,000 US$)

រដ្ឋាភិបាលជប៉ុនមានការសន្យាដ៏យូរណាស់មកហើយមួយ គឺការជួយធ្វើអោយប្រសើរឡើងដល់វិស័យទឹកស្អាតដើម្បីធានាដល់តម្រូវការជាមូលដ្ឋានរបស់ប្រជាជននៅប្រទេសកម្ពុជា ។ ឧទាហរណ៍ដូចជារោងចក្រផលិតទឹកស្អាត និងបណ្ដាញផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញដែលត្រូវបានកែលំអធ្វើអោយប្រសើរឡើងនៅបណ្ដាឆ្នាំ 1990-នៅខេត្តសៀមរាបនៅដើមឆ្នាំ 2000 និងនៅតំបន់ជុំវិញរាជធានី និង តំបន់ជនបទខេត្តដាច់ស្រយាល ។

នៅរាជធានីភ្នំពេញ រួមទាំងតំបន់ដែលនៅជុំវិញផងនោះ តម្រូវការទឹកស្អាតកាន់តែមានការកើនឡើងដោយសារកំណើនដ៏គួរអោយកត់សំគាល់នៃចំនួនប្រជាជន និង ស្ថានភាពពាណិជ្ជកម្ម ដែលទាមទារអោយមានការផ្គត់ផ្គង់ទឹកស្អាតដែលមានសុវត្ថិភាព និង ស្ថេរ កាន់តែច្រើនឡើង ។

គំរោងដែលចុះហត្ថលេខានៅថ្ងៃនេះ ត្រូវអនុវត្តដោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺដើម្បីសាសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតមួយ រួមទាំងបំាបនីយភណ្ឌដែលចាំបាច់ដទៃទៀតនៅសង្កាត់និរោធ ខ័ណ្ឌមានជ័យ ដើម្បីធ្វើអោយប្រសើរឡើងនូវស្ថានភាពរស់នៅ និង ការវិនិយោគ ។

លក្ខខណ្ឌនៃប្រាក់កម្ចីមានដូចតទៅ:

1- អត្រាការប្រាក់គឺ 0.01 % ក្នុងមួយឆ្នាំ

2- រយៈពេលកំណត់សងវិញ គឺ 40 ឆ្នាំ ដោយគិតទាំងរយៈពេលអនុគ្រោះ ចំនួន 10 ឆ្នាំ

3- លក្ខខណ្ឌនៃការផ្គត់ផ្គង់ គឺដោយការដេញថ្លៃជាអន្តរជាតិ

តាមរយៈការអនុវត្តន៍គំរោងនេះ យើងសង្ឃឹមថាសមត្ថភាពនៃការផ្គត់ផ្គង់ទឹកស្អាត និង គុណភាពទឹកនឹងត្រូវបានអភិវឌ្ឍន៍ឡើង ហើយចំនួនប្រជាជនដែលនឹងទទួលបាននូវទឹកស្អាតប្រើប្រាស់នឹងមានចំនួនកើនឡើងប្រមាណ 470.000 នាក់ ។

**2~ គំរោងផ្គត់ផ្គង់សំភារៈបោសសំអាតមីន (ដំណាក់កាលទី 5)**

(¥ 548,000,000 ប្រហាក់ប្រហែលស្មើនឹង US$ 5,480,000)

ដោយទទួលស្គាល់នូវមហន្តរាយយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីគ្រាប់មីនដែលមានយ៉ាងច្រើនកប់នៅក្នុងដីនៅប្រទេសកម្ពុជានោះ ចាប់តាំងពីឆ្នាំ 1999 មក រដ្ឋាភិបាលជប៉ុនបានគាំទ្រដល់សកម្មភាពបោសសំអាតមីនរបស់មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា（CMAC）ដោយបានផ្តល់សំភារៈបោសសំអាតមីនតាមរយៈជំនួយឥតសំណងរបស់ខ្លួន ហើយដោយរួមទាំងការចុះហត្ថលេខានៅថ្ងៃនេះផងនោះ ជំនួយឧបត្ថម្ភដល់ CMAC ទាំងអស់មានចំនួន **¥3,907,000,000** (ប្រហាក់ប្រហែលស្មើនឹង **US$ 34,800,000**) ។

ជំនួយឥតសំណងដែលបានផ្តល់នៅដំណាក់កាលទាំង 4 កាលពីលើកមុននោះមាន:

ដំណាក់កាលទី 1 ចុះហត្ថលេខានៅថ្ងៃទី 26 មិនា 1999 **: ¥ 470,000,000 (US$ 4 million)**

ដំណាក់កាលទី 2 ចុះហត្ថលេខានៅថ្ងៃទី 11 ឧសភា 2000 **:¥ 330,000,000 (US$ 3 million)**

ដំណាក់កាលទី 3 ចុះហត្ថលេខានៅថ្ងៃទី 13 មិថុនា 2002 **:¥ 798,000,000 (US$ 6.3 million)**

ដំណាក់កាលទី 4 ចុះហត្ថលេខានៅថ្ងៃទី 11 សីហា 2004 **:¥ 1,761,000,000 (US$ 16 million)**

សំភារៈបោសសំអាតមីនដែលត្រូវផ្តល់ជូននៅដំណាក់កាលទី 5 នេះ រួមមានម៉ាស៊ីនរាវរកមីន-ម៉ាស៊ីនរាវរកមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ-គ្រឿងបន្លាស់ និង រោងជាងចល័តសំរាប់ម៉ាស៊ីនកាត់ស្មៅជាមួយដងស្ទូច ។ យើងសង្ឃឹមថាគំរោងផ្គត់ផ្គង់សំភារៈបោសសំអាតមីនដំណាក់កាលទី 5 នេះ នឹងជួយពន្លឿនសកម្មភាពបោសសំអាតមីនរបស់ CMAC ហើយជាលទ្ធផលនោះគឺនឹងមានប្រជាជនកម្ពុជាកាន់តែច្រើននាក់ឡើងអាចរស់នៅដោយសុខសន្តិភាពនៅលើដីដែលបានបោសសំអាតមីនរួច ។

**ស្ថានទូតជប៉ុន លេខ 194 មហាវិថីព្រះនរោត្តម ទូរស័ព្ទ: 023.21.71.61-4 ហ្វាក់: 023.21.61.62**
**Email Address: keikyou. eojc@online.com.kh**
**Official website: www.kh.emb-japan.go.jp**

# ជំនួយឧបត្ថម្ភរបស់ជប៉ុនសំរាប់សកម្មភាពបោសសំអាតមីននៅកម្ពុជា

(ពីឆ្នាំ 1994 រហូតដល់បច្ចុប្បន្ន)

| | **ប្រភេទជំនួយ** | **ជាប្រាក់ដុល្លារអាមេរិក**<br>(ប្រហាក់ប្រហែល) |
|---|---|---|
| 1 | ជំនួយឥតសំណងទ្វេភាគី ដល់ CMAC (¥ 3,907,000,000) | 34,800,000 |
| 2 | មូលនិធិទំនុកចិត្ត UNDP | 11,500,000 |
| 3 | មូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន (JAIF) | 376,910 |
| 4 | កម្មវិធីកសាងសន្តិភាព និង គ្រប់គ្រងអាវុធធន់តូចនៅប្រទេសកម្ពុជា (¥ 910,000,000¦ | 8,500,000 |
| 5 | ជំនួយឥតសំណងសំរាប់គំរោងការសន្តិសុខមនុស្សជាតិខ្នាតតូច ដល់ CMAC | 11,301,368 |
| 6 | ជំនួយឧបត្ថម្ភជប៉ុនសំរាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍បច្ចេកវិជ្ជាថ្មី (គំរោងស្រាវជ្រាវ និង អភិវឌ្ឍន៍ឧបករណ៏បោសសំអាតមីន (ដំណាក់កាលទី 1: ¥ 416,000,000) (ដំណាក់កាលទី 2 : ¥ 484,000,000) ដល់ CMAC | 7,789,000 |
| 7 | ជំនួយឥតសំណងសំរាប់គំរោងការខ្នាតតូច/សន្តិសុខមនុស្សជាតិសំរាប់អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងសកម្មភាពបោសសំអាតមីនៈ<br>- អង្គការហាឡូត្រឹស្ត (US$4,743,191)<br>- អង្គការ JAHDS (US$580,,858)<br>- អង្គការ ទីប្រឹក្សាដោះមីន (US$4,954,987) | 10,279,036 |
| 8 | ជំនួយឥតសំណងសំរាប់គំរោងការខ្នាតតូច/សន្តិសុខខ្នាតមនុស្សជាតិសំរាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលធ្វើការក្នុងសកម្មភាពបោសសំអាតមីនៈ<br>- អង្គការ JMAS (US$5,692,624) | 5,692,624 |
| 9 | គំរោងផ្តល់សំភារៈអង្កេតតំបន់មានគ្រាប់មីនសំរាប់អភិវឌ្ឍន៏ក្រុងប៉ៃលិន | 5,536 |
| | **សរុប** | **90,244,474** |

**ស្ថានទូតជប៉ុន លេខ 194 មហាវិថីព្រះនរោត្តម ទូរស័ព្ទៈ 023.21.71.61-4 ហ្វាក់ៈ 023.21.61.62**
**Email Address: keikyou.eojc@online.com.kh**
**Official website: www.kh.emb-japan.go.jp**